# ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

Ministry of Social Affairs, Veterans and Youth Rehabilitation

# ថវិកាពលរដ្ឋឆ្នាំ២០២៦

Citizen Budget Fiscal Year 2026




https://mosvy.gov.kh/ | @mosvycambodia | mosvycambodiaofficial | mosvycambodia

អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

Building 788, Monivong Blvd, Sangkat Boeung Trabek, Khan Chamkamorn, Phnom Penh


## ១.សេចក្តីផ្តើម

ថវិកាប្រជាពលរដ្ឋគឺជាឯកសារផ្សព្វផ្សាយព័ត៌មានថវិកាប្រចាំឆ្នាំជូនដល់អ្នកទទួលផលពីសេវាសាធារណៈដែលផ្តល់ដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ)ដើម្បីលើកកម្ពស់ទំនាក់ទំនងរវាងក្រសួង ជាមួយសាធារណជនទូទៅ។

## ២.សេវាសាធារណៈ

ក្រសួង ស.អ.យ បំពេញបេសកកម្មជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការដឹកនាំនិងគ្រប់គ្រងវិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានិងទទួលខុសត្រូវផ្តល់សេវាសាធារណៈចម្បងៗដែលអនុលោមតាមលិខិតបទដ្ឋានគតិយុត្តមានដូចខាងក្រោម៖

### ក.សេវាសង្គមកិច្ច

- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ដល់ជនរងគ្រោះដោយដាច់ស្បៀង ទីទ័លក្រ គ្រោះធម្មជាតិ និងគ្រោះមហន្តរាយដោយយថាហេតុនៅតាមសហគមន៍
- ផ្តល់សេវាថែទាំ គាំទ្រដល់ជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ និងជំងឺកាចសាហាវផ្សេងៗនៅតាមសហគមន៍
- ដោះស្រាយបញ្ហា ទប់ស្កាត់ និងការពារជនអនាថា
- ផ្តល់សេវាថែទាំ ព្យាបាល និងស្តារនីតិសម្បទាជនវិបល្លាសស្មារតី
- មាតុភូមិនិវត្ត ស្តារនីតិសម្បទានិងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្សអំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងៗទៀតនៃការរំលោភបំពាន
- ថែទាំជំនួសចំពោះកុមារ
- សុំកូនក្នុងប្រទេស សុំកូនអន្តរប្រទេស
- បណ្តុះបណ្តាលវិជ្ជាជីវៈជូនជនពិការ
- អន្តរាគមន៍សេវាយុត្តិធម៌សម្រាប់ជនមានពិការភាព

### ខ.សេវាស្តារសម្បទា

- ស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្សនិងសមាហរណកម្មជនរងគ្រោះ
- ស្តារនីតិសម្បទាជនរងគ្រោះដោយសារការប្រើប្រាស់គ្រឿងញៀន
- ស្តារនីតិសម្បទាអនីតិជនទំនាស់នឹងច្បាប់
- កម្មវិធីបង្វែរអនីតិជនទំនាស់នឹងច្បាប់
- ស្តារលទ្ធភាពពលកម្មកាយសម្បទា និងវេជ្ជសាស្ត្រជូនជនមានពិការភាព
- ផ្តល់របបគោលនយោបាយ ផ្នែកពិនិត្យ ព្យាបាលនិងថែទាំសុខភាពជនពិការក្រីក្រតាមសហគមន៍

### គ.ប្រព័ន្ធគាំពារសង្គម

- បើកផ្តល់របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល និវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈនិងអ្នកនៅក្នុងបន្ទុក
  - បើកផ្តល់របបសន្តិសុខសង្គម ជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជន
  - អនុវត្តកម្មវិធីជាតិជំនួយសង្គមក្នុងកញ្ចប់គ្រួសារតាមរយៈ៖
    - ការឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម២ឆ្នាំ
    - ការឧបត្ថម្ភសាច់ប្រាក់ជូនជនមានពិការភាព
    - ការឧបត្ថម្ភសាច់ប្រាក់ជូនជនចាស់ជរា(អាយុ៦០ឆ្នាំឡើង) និង
    - ការរួមបញ្ចូលការឧបត្ថម្ភគោលសម្រាប់គ្រួសារនិងឧបត្ថម្ភ សមាជិកគ្រួសារអ្នកផ្ទុកមេរោគអេដស៍និងជំងឺអេដស៍ ដែលបានចាប់ផ្តើមអនុវត្តជាផ្លូវការនៅក្នុងអំឡុងខែមេសាឆ្នាំ២០២៤។



## ៣.គោលបំណងគោលនយោបាយ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដាក់ចេញនូវគោលនយោបាយ “ការលើកកម្ពស់កិច្ចគាំពារសង្គម និងសេវាសង្គមដើម្បីលើកស្ទួយស្ថានភាពសង្គមសេដ្ឋកិច្ច” ក្នុងគោលបំណង “លើកកម្ពស់គុណភាព ប្រសិទ្ធភាព និងសមធម៌សេវាសង្គមកិច្ច និងកិច្ចគាំពារសង្គមសម្រាប់គ្រួសារក្រីក្រ ជនរងគ្រោះនិងងាយរងគ្រោះ” ។ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានរៀបចំរចនាសម្ព័ន្ធកម្មវិធីចំនួន ៤ ដូចខាងក្រោម៖

| ឈ្មោះកម្មវិធី | អនុកម្មវិធី | ចង្កោមសកម្មភាព |
|---|---|---|
| កម្មវិធីទី១៖ លើកកម្ពស់សេវាសង្គមកិច្ច | ៥ | ២២ |
| កម្មវិធីទី២៖ ការគ្រប់គ្រងសេវាស្តារជនរងគ្រោះ | ៦ | ២៤ |
| កម្មវធីទី៣៖ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម | ៤ | ១៧ |
| កម្មវិធីទី៤៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ | ៦ | ១៩ |
| សរុបអនុកម្មវិធីនិងចង្កោមសកម្មភាព | ២១ | ៨២ |

យោងតាមច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២៤ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលឥណទានថវិកាសរុប ចំនួន ២ ៣១៤ ៦៤៥ លានរៀល និងបានកំណត់នូវសូចនាករគន្លឹះដើម្បីតាមដានវឌ្ឍនភាពនិងសមិទ្ធផលនៃការអនុវត្តកម្មវិធី និងគោលបំណងគោលនយោបាយនីមួយៗដូចខាងក្រោម៖

### កម្មវិធីទី១ ៖ លើកកម្ពស់សេវាសង្គមកិច្ច

គោលបំណងកម្មវិធី ៖បង្កើនការពេញចិត្តរបស់ជនរងគ្រោះនិងងាយរងគ្រោះ និងការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមានរបស់បុគ្គលនិងគ្រួសារបន្ទាប់ពីទទួលសេវាសង្គមកិច្ច។

សូចនាករលទ្ធផលចុងក្រោយ (KPI)

| KPI-101 | មធ្យមភាគនៃកម្រិតពេញចិត្តរបស់អតិថិជនលើសេវាសង្គមកិច្ច |
|---|---|
| KPI-102 | ភាគរយនៃករណីដែលបានធ្វើសមាហរណកម្មជោគជ័យនៅក្នុងសហគមន៍ |

អនុកម្មវិធីទី១.១ ៖លើកកម្ពស់សេវាគាំពារមនុស្សចាស់និងអតីតយុទ្ធជន

អនុកម្មវិធីទី១.២ ៖លើកកម្ពស់សេវាកិច្ចការពារកុមារ

អនុកម្មវិធីទី១.៣ ៖លើកកម្ពស់កិច្ចការគ្រួសារ

អនុកម្មវិធីទី១.៤ ៖លើកកម្ពស់សេវាគាំពារជនរងគ្រោះ

អនុកម្មវិធីទី១.៥ ៖សេវាគាំទ្រការលើកកម្ពស់សេវាសង្គមកិច្ច រាជធានី ខេត្ត

ឥណទានថវិកាគាំទ្រសកម្មភាព **កម្មវិធីទី១** ទឹកប្រាក់សរុបចំនួន**៣៥ ៦២៥,៥** លានរៀល




## កម្មវិធីទី២ ៖ ការគ្រប់គ្រងសេវាស្តារនីតិសម្បទាជនរងគ្រោះ

**គោលបំណងកម្មវិធី** ៖បង្កើនការពេញចិត្តរបស់ជនរងគ្រោះនិងការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមានរបស់បុគ្គលនិងគ្រួសារបន្ទាប់ពីទទួលសេវាស្តារសម្បទា។

សូចនាករលទ្ធផលចុងក្រោយ (KPI)៖

| KPI-201 | មធ្យមភាគនៃកម្រិតពេញចិត្តរបស់អតិថិជនលើសេវាស្តារសម្បទា |
|---|---|
| KPI-202 | ភាគរយនៃករណីដែលបានធ្វើសមាហរណកម្មជោគជ័យនៅក្នុងសហគមន៍ |

អនុកម្មវិធីទី២.១ ៖លើកកម្ពស់សេវាស្តារនីតិសម្បទាអនីតិជន

អនុកម្មវិធីទី២.២ ៖លើកកម្ពស់សេវាស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

អនុកម្មវិធីទី២.៣ ៖លើកកម្ពស់សុខុមាលភាពជនមានពិការភាព

អនុកម្មវិធីទី២.៤ ៖កៀរគរ និងប្រើប្រាស់មូលនិធិសង្គមកិច្ច

អនុកម្មវិធីទី២.៥ ៖លើកម្ពស់សេវាស្តារលទ្ធភាពពលកម្មជូនជនមានពិការភា

អនុកម្មវិធីទី២.៦ ៖សេវាគាំទ្រការគ្រប់គ្រងសេវាស្តារជនរងគ្រោះ រាជធានី ខេត្ត

ឥណទានថវិកាគាំទ្រសកម្មភាព **កម្មវិធីទី២** ទឹកប្រាក់សរុបចំនួន**៣៤ ៣៣៥,៣** លានរៀល




## កម្មវិធីទី៣ ៖ សេវាគាំទ្រការអនុវត្តកម្មវិធីគាំពារសង្គម

**គោលបំណងកម្មវិធី** ៖បង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាគាំពារសង្គមដល់អតីតយុទ្ធជន អតីតមន្ត្រីរាជការស៊ីវិល អ្នកនៅក្នុងបន្ទុក និងគ្រួសារក្រីក្រនិងងាយរងគ្រោះ។

សូចនាករលទ្ធផលចុងក្រោយ(KPI)៖

| KPI-301 | ភាគរយនៃអ្នកទទួលផលដែលពេញចិត្តលើសេវារបស់ មជជ |
|---|---|

អនុកម្មវិធីទី៣.១ ៖លើកកម្ពស់សេវាបើកផ្តល់តាមកាលិកនិងរបបគោលនយោបាយ

អនុកម្មវិធីទី៣.២ ៖លើកកម្ពស់សមត្ថភាពស្ថាប័ន និងការផ្សព្វផ្សាយ

អនុកម្មវិធីទី៣.៣ ៖អភិវឌ្ឍន៍គោលនយោបាយ និងកិច្ចការនីតិកម្មគាំពារសង្គម

អនុកម្មវិធីទី៣.៤ ៖សេវាគាំទ្រកិច្ចដំណើរការអនុវត្តកម្មវិធីគាំពារសង្គម

ឥណទានថវិកាគាំទ្រសកម្មភាព **កម្មវិធីទី៣** ទឹកប្រាក់សរុបចំនួន**២ ៤៤៣ ៨៣៧,១** លានរៀល




## កម្មវិធីទី៤ ៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ

**គោលបំណងកម្មវិធី** ៖ពង្រឹងប្រសិទ្ធភាពនិងសក្តិសិទ្ធភាពសេវាគាំទ្រការងារផែនការ ធនធានមនុស្ស ហិរញ្ញវត្ថុ អធិការកិច្ច និងអភិបាលកិច្ចសេវាសង្គមកិច្ច ស្តារសម្បទា និងជំនួយសង្គម។

សូចនាករលទ្ធផលចុងក្រោយ (KPI)៖

| KPI-401 | កម្រិតពេញចិត្តជាមធ្យមរបស់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងលើសេវាគាំទ្រ |
|---|---|
| KPI-402 | ប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យផ្ទៃក្នុង |
| KPI-403 | ភាគរយនៃការអនុវត្តថវិកាធៀបនឹងច្បាប់ប្រចាំឆ្នាំ |

អនុកម្មវិធីទី៤.១ ៖លើកកម្ពស់សមត្ថភាពស្ថាប័ន និងអភិបាលកិច្ច

អនុកម្មវិធីទី៤.២ ៖អភិវឌ្ឍន៍ធនធានមនុស្សវិស័យសង្គមកិច្ច

អនុកម្មវិធីទី៤.៣ ៖លើកកម្ពស់ការអភិវឌ្ឍគោលនយោបាយសង្គមកិច្ច

អនុកម្មវិធីទី៤.៤ ៖លើកកម្ពស់ការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ

អនុកម្មវិធីទី៤.៥ ៖លើកកម្ពស់ការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិជនពិការ

អនុកម្មវិធីទី៤.៦ ៖សេវាគាំទ្រទូទៅ និងអភិបាលកិច្ចវិស័យសង្គមកិច្ចរាជធានី-ខេត្ត

ឥណទានថវិកាគាំទ្រសកម្មភាព **កម្មវិធីទី៤** ទឹកប្រាក់សរុបចំនួន**៦០ ៦០០,១** លានរៀល

